ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:០១ សលខ

# សារលិខិត

## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
## នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
## ផ្ញើជូន
## អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ក្នុងឱកាសទិវានៃពិធីជំនួបរវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជាមួយអ្នកសារព័ត៌មានកម្ពុជា លើកទី៦
## ថ្ងៃទី១៤ ខែមករា ឆ្នាំ២០២២

*បងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ជាទីស្រលាញ់រាប់អាន!*

*ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និងខ្លួនខ្ញុំផ្ទាល់ មានសេចក្តីសោមនស្សរីករាយដែលបានផ្ញើសារចូលរួមអបអរសាទរជូនបងប្អូនអ្នកសារព័ត៌មានជាតិ និងអន្តរជាតិ ដែលកំពុងបំពេញការងារលើវិស័យព័ត៌មាននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសទិវាជំនួបរវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជាជាមួយអ្នកសារព័ត៌មានកម្ពុជា ដែលជាទម្លាប់ត្រូវបានប្រារព្ធធ្វើឡើងនាថ្ងៃទី១៤ ខែមករា រៀងរាល់ឆ្នាំ ហើយក៏សូមអធ្យាស្រ័យចំពោះបងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលរយៈពេលពីរឆ្នាំចុងក្រោយនេះរាជរដ្ឋាភិបាលអាក់ខានមិនបានរៀបចំពិធីជួបជុំដ៏មានសារៈសំខាន់ ដោយសារការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ទ្រង់ទ្រាយធំចូលក្នុងសហគមន៍របស់យើង។*

*ថ្វីត្បិតតែរាជរដ្ឋាភិបាលសម្រេចបិទបញ្ចប់ព្រឹត្តិការណ៍សហគមន៍ ២០ កុម្ភៈ ដែលជារលកទី៣ នៃការឆ្លងចូលសហគមន៍ទ្រង់ទ្រាយធំ ហើយបើកប្រទេសឡើងវិញ និងបើកឱ្យដំណើរការលើគ្រប់វិស័យ ព្រមទាំងបើកឱ្យមានពិធីជួបជុំឡើងវិញក៏ដោយ ក៏បញ្ហានេះមិនអាចឱ្យយើងរៀបចំពិធីជួបជុំទ្រង់ទ្រាយធំដែលមានមនុស្សចូលរួមរហូតដល់រាប់ពាន់នាក់នៅក្នុងបរិវេណដែលគ្មានសុវត្ថិភាព និងខ្វះការប្រុងប្រយ័ត្នចំពោះឱកាសវិលត្រឡប់មកវិញនៃជំងឺដ៏កាចសាហាវនេះបានឡើយ។*

*ឆ្នាំ២០២២នេះ គឺជាខួបលើកទី៦ ដែលត្រូវរៀបចំពិធីជំនួបរវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជាជាមួយអ្នកសារព័ត៌មានកម្ពុជា ក្នុងនាមប្រជាជាតិខ្មែរតែមួយក្នុងគោលបំណងបង្កើនសាមគ្គីភាព និងពង្រឹងភាពជាដៃគូរវាងរាជរដ្ឋាភិបាលកម្ពុជា ជាមួយស្ថាប័នសារព័ត៌មានទាំងអស់ ដើម្បីលើកកម្ពស់សិទ្ធិសេរីភាពខាង*

សារព័ត៌មាន និងជានាបាននូវសុខដុមនីយកម្មក្នុងសង្គម រក្សាសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងជំរុញការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់យើង។

ខ្ញុំសូមយកឱកាសនេះថ្លែងនូវការកោតសរសើរដោយស្មោះចំពោះបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលខិតខំបំពេញការកិច្ចអស់រយៈពេលមួយឆ្នាំកន្លងមកនេះ ក្នុងការផ្សព្វផ្សាយព័ត៌មានអំពីសភាពការណ៍ពិតនៅកម្ពុជា ជាពិសេសចូលរួមចំណែកផ្សព្វផ្សាយនូវយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស និងវិធានការរបស់រាជរដ្ឋាភិបាល ព្រមទាំងវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីបង្ការទប់ស្កាត់ និងកាត់ផ្តាច់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ ចូលក្នុងសហគមន៍បានរហ័សទាន់សភាពការណ៍ និងមានប្រសិទ្ធភាព ដែលរហូតមកដល់ពេលនេះយើងបានចាក់វ៉ាក់សាំងជូនប្រជាជនបានចំនួនជាង ១៥លាននាក់ ក្នុងចំណោមប្រជាជនជាង១៦លាននាក់ ហើយយើងបានបើកយុទ្ធនាការចាក់វ៉ាក់សាំងកូវីដ-១៩ ដូសទី៣ (ដូសជំរុញ) នៅទូទាំងប្រទេស និងមានការចូលរួមគាំទ្រពីប្រជាពលរដ្ឋទៅចាក់វ៉ាក់សាំងយ៉ាងច្រើនលើសលប់ ថ្វីត្បិតតែមានការឃោសនាពាំងយុទ្ធនាការចាក់វ៉ាកសាំងពីក្រុមអគតិដើម្បីបំផ្លាញសេចក្តីសុខរបស់ប្រជាជនកម្ពុជាយើងក៏ដោយ។

ជាមួយនឹងជោគជ័យនៃការចាក់វ៉ាក់សាំងជូនប្រជាពលរដ្ឋនៅទូទាំងប្រទេស និងការថយចុះជាលំដាប់នៃអត្រាអ្នកឆ្លង និងគ្មានអ្នកស្លាប់ដោយសារកូវីដ-១៩ ព្រឹត្តិការណ៍២០ កុម្ភៈ នៅក្នុងដំណាក់កាលចុងក្រោយនេះ រាជរដ្ឋាភិបាលសម្រេចបិទបញ្ចប់ព្រឹត្តិការណ៍២០កុម្ភៈ ដែលជាព្រឹត្តិការណ៍សោកនាដកម្មសម្រាប់ប្រទេសរបស់យើងដែលក្នុងរយៈពេល១០ខែ ចាប់ពីថ្ងៃទី២០ ខែកុម្ភៈ ដល់ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០២១ មានប្រជាជនកម្ពុជាឆ្លងជំងឺកូវីដ-១៩ រហូតដល់ចំនួន១២៤ ០២៣នាក់ និងបាត់បង់ជីវិត៣ ០០៥នាក់ ហើយពីមួយថ្ងៃៗមានអ្នកឆ្លងកូវីដ-១៩ ជាងមួយពាន់នាក់ និងស្លាប់រាប់សិបនាក់ ថយចុះមកនៅត្រឹមមានអ្នកឆ្លងក្នុងមួយថ្ងៃក្រោម១០នាក់ និងគ្មានមនុស្សស្លាប់ដែលអាចឱ្យរដ្ឋាភិបាលសម្រេចចិត្តបិទបញ្ចប់ព្រឹត្តិការណ៍២០ កុម្ភៈ ហើយបើកប្រទេសឡើងវិញនិងបើកឱ្យដំណើរការលើគ្រប់វិស័យ ព្រមទាំងអនុញ្ញាតឱ្យបើកពិធីជួបជុំឡើងវិញដែលជាឱកាសសម្រាប់ស្តារសេដ្ឋកិច្ចជាតិបន្ទាប់ពីត្រូវបានបំផ្លាញដោយសារកូវីដ-១៩ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ។

មួយវិញទៀត ខ្ញុំក៏សូមកោតសរសើរចំពោះសមាគមអ្នកសារព័ត៌មានទាំងអស់ដែលបានខិតខំប្រឹងប្រែងបណ្តុះបណ្តាលវិជ្ជាជីវៈ និងតម្រង់ទិសអ្នកសារព័ត៌មានទាំងអស់ឱ្យធ្វើជាកញ្ចក់ឆ្លុះបញ្ចាំងតថភាព ក្នុងសង្គម និងការបំពេញការកិច្ចប្រកបដោយក្រមសីលធម៌ វិជ្ជាជីវៈដើម្បីលើកកម្ពស់តម្លៃ និងកិត្យានុភាពរបស់ស្ថាប័នព័ត៌មាននិងអ្នកសារព័ត៌មានទូទៅ។

## បងប្អូនអ្នកសារព័ត៌មានជាទីស្រឡាញ់រាប់អានទាំងអស់គ្នា

រាជរដ្ឋាភិបាលពិតជាបានដឹងអំពីការលំបាករបស់បងប្អូនទាំងផ្នែកហិរញ្ញវត្ថុ និងការបំពេញការកិច្ចដោយសារវិបត្តិកូវីដ-១៩ ក្នុងរយៈពេលពីរឆ្នាំកន្លងមកនេះ។ យើងដឹងហើយថា សារព័ត៌មានវិជ្ជាជីវៈអាចរស់បានដោយសារពឹងផ្អែកទៅលើការផ្សាយពាណិជ្ជកម្ម ដែលកើតចេញពីការរីកលូតលាស់នៃសេដ្ឋកិច្ចជាតិ។ វិបត្តិកូវីដ-១៩ រយៈពេលពីរឆ្នាំកន្លងមកនេះ បានបំផ្លាញសេដ្ឋកិច្ចកម្ពុជាជិតបីពាន់លានដុល្លារអាមេរិក

ហើយការបិទខ្ទប់ប្រទេសមួយរយៈពេលនាពេលកន្លងមក បានធ្វើឱ្យប្រជាពលរដ្ឋរួមទាំងអ្នកសារព័ត៌មានរបស់យើងជួបបញ្ហាវិបត្តិហិរញ្ញវត្ថុនិងមានការលំបាកក្នុងការបំពេញការកិច្ច។ ប៉ុន្តែក្រោយពីស្ថានភាពកូវីដ-១៩ អាចគ្រប់គ្រងបាននិងការបិទបញ្ចប់រលកទី៣ ព្រឹត្តិការណ៍២០ កុម្ភៈ ជាឱកាសបើកប្រទេសនិងបើកដំណើរការឡើងវិញលើគ្រប់វិស័យ ពិតជាបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជា ដំណើរការឡើងវិញជាមួយនឹងកំណើនខ្ពស់ដែលជួយធ្វើឱ្យជីវភាពរបស់ប្រជាពលរដ្ឋកម្ពុជា មានភាពល្អប្រសើរនៅពេលខាងមុខហើយក៏បានផ្តល់ភាពងាយស្រួលដល់បងប្អូនចុះបំពេញការងារផងដែរ។

ជាមួយវឌ្ឍនភាពនិងជោគជ័យដែលយើងសម្រេចបាននាពេលកន្លងមក ក៏មានកិច្ចការជាច្រើនទៀតដែលស្ថាប័នព័ត៌មានត្រូវចូលរួមបំពេញនាពេលខាងមុខដូចជា ការរៀបចំកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងការរៀបចំប្រកួតកីឡាអាស៊ីអាគ្នេយ៍លើកទី៣២ ឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះសុទ្ធតែជាព្រឹត្តិការណ៍សំខាន់ៗ និងជាប្រវត្តិសាស្ត្រសម្រាប់កម្ពុជា ដែលអ្នកសារព័ត៌មានទាំងអស់ត្រូវត្រៀមលក្ខណៈចូលរួមផ្សព្វផ្សាយទៅកាន់សកលលោកបង្ហាញអំពីការវិវត្តរបស់កម្ពុជា។ ក្រៅពីនេះក៏មានកិច្ចការជាច្រើនទៀតដែលត្រូវធ្វើ ខ្ញុំសូមយកឱកាសនេះផ្តល់អនុសាសន៍ដល់អ្នកសារព័ត៌មានដើម្បីអនុវត្តបន្ត៖

១- ស្ថាប័នព័ត៌មានរដ្ឋ និងឯកជនត្រូវចូលរួមរក្សាសន្តិភាព ស្ថេរភាពនយោបាយ សន្តិសុខសណ្តាប់ធ្នាប់សង្គម តាមរយៈ **ភូមិ ឃុំ មានសុវត្ថិភាព** ដោយធ្វើការផ្សព្វផ្សាយជំរុញឱ្យអាជ្ញាធរ និងស្ថាប័នមានសមត្ថកិច្ច ទប់ស្កាត់ និងចាត់វិធានការលើបទល្មើសគ្រឿងញៀន ល្បែងស៊ីសងគ្រប់ប្រភេទ ក្មេងទំនើងចោរប្លន់ប្រដាប់អាវុធ គ្រោះថ្នាក់ចរាចរជាដើម ដែលកើតឡើងនៅក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីកសាងសង្គមកម្ពុជាឱ្យមានសុវត្ថិភាព សណ្តាប់ធ្នាប់សង្គម និងរក្សាកិត្តិយស សេចក្តីថ្លៃថ្នូរ លើកមុខមាត់កម្ពុជាលើឆាកអន្តរជាតិក្នុងនាមកម្ពុជាធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ានឆ្នាំ២០២២ និងការប្រកួតកីឡាស៊ីហ្គេមឆ្នាំ២០២៣។

២- ចូលរួមផ្សព្វផ្សាយកិច្ចប្រជុំអាស៊ានឆ្នាំ២០២២ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ និងបើកយុទ្ធនាការផ្សព្វផ្សាយព្រឹត្តិការណ៍ប្រកួតកីឡាស៊ីហ្គេម (Sea Games) លើកទី៣២ និងកីឡាអាស៊ានប៉ារ៉ាហ្គេម (ASEAN Para Games) ឆ្នាំ២០២៣ ឱ្យបានផុសផុលដើម្បីបំផុសស្មារតីនិងលើកទឹកចិត្តដល់កីឡាករ កីឡាការិនី យុវជន និងប្រជាពលរដ្ឋយើងឱ្យគាំទ្រនិងស្នេហាវិស័យកីឡាក្រោមពាក្យស្លោក "**កីឡារស់ក្នុងសន្តិភាព**" "**កីឡានាំមកនូវមិត្តភាព**" "**កីឡាដើម្បីសុខភាព**" "**កម្ពុជាកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍**" "**កម្ពុជាស្អាត**"។

៣- ស្ថាប័នព័ត៌មាន ក៏ដូចជាអ្នកសារព័ត៌មានត្រូវបង្កើនភាពជាដៃគូជាមួយរាជរដ្ឋាភិបាល ដោយត្រូវបំពេញតួនាទីជាស្ពានចម្លងផ្សារភ្ជាប់ទំនាក់ទំនងពីស្ថាប័នរដ្ឋទៅប្រជាជននិងពីប្រជាជនមកស្ថាប័នរដ្ឋវិញទាំងកម្មវិធីគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាំងការអនុវត្តជាក់ស្តែងដែលតម្រូវឱ្យអ្នកសារព័ត៌មានរបស់យើងចូលរួមឱ្យកាន់តែសកម្មថែមទៀត។

៤- បន្តចូលរួមប្រយុទ្ធជាមួយភាពអសកម្ម ភាពមិនប្រក្រតី អំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គមដើម្បីកសាងកម្ពុជា ជាសង្គមមួយដែលស្អាតស្អំ មានតម្លាភាព សុំឱ្យអ្នកសារព័ត៌មានរបស់

យើងចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងពេលដែលរាជរដ្ឋាភិបាលកំពុងជម្រុញកំណែទម្រង់រដ្ឋ ដើម្បីឱ្យមាន
តម្លាភាពដែលទាមទារឱ្យអ្នកសារព័ត៌មានបំពេញតួនាទីតាមវិជ្ជាជីវៈ មានសមត្ថភាព និងសិក្សាបញ្ហាដល់
ទីជម្រៅ ហ៊ានបញ្ចេញនូវព័ត៌មានពិត មិនក្លែងបន្លំ បំភ្លៃការពិត និងត្រូវបន្តបំផ្លាញចោលពួកឱកាសនិយម
ស្វែងយកផលប្រយោជន៍ផ្ទាល់ខ្លួនជ្រកក្រោមស្លាកសារព័ត៌មានធ្វើឱ្យប៉ះពាល់ដល់តម្លៃ កិត្យានុភាពរបស់
អ្នកសារព័ត៌មានទូទៅនិងស្ថាប័នសារព័ត៌មាន។

៥- បន្តចូលរួមប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយទាំងនៅក្របខ័ណ្ឌជាតិ និង
អន្តរជាតិ ដែលបច្ចុប្បន្ន តំណាងសារព័ត៌មានរបស់យើងក៏មាននៅក្នុងក្របខណ្ឌស្ថាប័នព័ត៌មានអាស៊ាន
ដែលតម្រូវឱ្យស្ថាប័នព័ត៌មានរបស់យើងធ្វើការប្រយុទ្ធប្រឆាំងព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយឱ្យកាន់
តែសកម្មថែមទៀត ព្រោះព័ត៌មានមិនពិត និងព័ត៌មានក្លែងក្លាយ ជាផ្នែកចិត្តសាស្ត្រដែលអាចធ្វើឱ្យសង្គម
ទាំងមូលមានភាពចលាចល អស្ថេរភាពនយោបាយ អសន្តិសុខសង្គម និងកើតមានអរិភាពជាមួយបរទេស។

៦- សមាគមអ្នកសារព័ត៌មានទាំងអស់ត្រូវបន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការ
បណ្តុះបណ្តាលវិជ្ជាជីវៈ សមត្ថភាពជំនាញដល់បុគ្គលិក និងភ្នាក់ងាររបស់ខ្លួនឱ្យដើរទាន់ការវិវត្តនៃបច្ចេកវិទ្យា
ប្រព័ន្ធផ្សព្វផ្សាយឌីជីថលដែលអាចជួយបំពេញការងារបានរហ័សទាន់សភាពការណ៍ និងត្រូវបង្កើតឡើង
នូវកាលានុវត្តភាពថ្មីមួយសម្រាប់ទប់ទល់នឹងបញ្ហាប្រឈមនានា ដែលអាចនឹងកើតមាននៅពេលអនាគត
ដែលមិនអាចប៉ាន់ស្មានបាន។ យើងត្រូវចាំថា ប្រសិនបើយើងមានឧបករណ៍ សម្ភារៈទំនើបប៉ុន្តែយើងមិន
មានធនធានមនុស្សសម្រាប់ប្រើប្រាស់ក៏មិនអាចមានការរីកចំរើនបានដែរ ជាពិសេសសារព័ត៌មានប្រពៃណី
ត្រូវអភិវឌ្ឍខ្លួនដើម្បីឈរជើងប្រកួតប្រជែងទីផ្សារជាមួយប្រព័ន្ធផ្សព្វផ្សាយទំនើប។

៧- ចូលរួមប្រយុទ្ធប្រឆាំងជំងឺឆ្លងកូវីដ-១៩ ដោយធ្វើការផ្សព្វផ្សាយនូវព័ត៌មានអប់រំ និងវិធានការ
របស់រាជរដ្ឋាភិបាល "**៣កុំ ៣ការពារ**" និងវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានខ្ជាប់ខ្ជួនដើម្បីទប់ស្កាត់
លុបបំបាត់ការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩ គ្រប់ប្រភេទចូលក្នុងសហគមន៍របស់យើង។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់បងប្អូនអ្នកសារព័ត៌មានជាតិនិងអន្តរជាតិ ដែលកំពុងបំពេញការងារ
នៅក្នុងព្រះរាជាណាចក្រកម្ពុជា សូមទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចរបស់ខ្លួន និងជួបប្រទះ
ពុទ្ធពរទាំងប្រាំប្រការគឺ: **អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ** កុំបីឃ្លៀងឃ្លាតឡើយ។

ថ្ងៃអង្គារ ៩កើត ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មករា ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**